## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ.ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ៤៨៤ អយក.ប្រក

## ស្តីពី

## ការកំណត់ខេត្ត.ក្រុងដាច់ស្រយាល និងតំបន់ជួបការលំបាក

~~~

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួង អប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

**ប្រការ ១** :ខេត្ត-ក្រុង ដូចមានរាយឈ្មោះខាងក្រោម ត្រូវបានកំណត់ថា ជាខេត្ត-ក្រុង ដាច់ស្រយាល គឺ :-
ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកោះកុង និង ក្រុងប៉ៃលិន ។

**ប្រការ ២** : តំបន់ជួបការលំបាក ត្រូវបានកំណត់តាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

- តំបន់ជួបប្រទះការលំបាកខាងគមនាគមន៍
~~~

- ដង់ស៊ីតេប្រជាជនតិចជាង ១០នាក់ ក្នុង១ គីឡូម៉ែត្រក្រឡា
- តំបន់ទឹកលិចអចិន្ត្រៃយ៍
- តំបន់សមាហរណកម្ម ឬតំបន់ជាប់ព្រំដែន
- តំបន់ដែលមានសាលារៀនមិនគ្រប់ក៏រិត ឬខ្វះគ្រូ ឬមានគ្រូកិច្ចសន្យា

**ប្រការ ៣** : តំបន់ក្នុងខេត្ត-ក្រុងខាងក្រោម ត្រូវបានកំណត់ថាជាតំបន់ជួបការលំបាក :

**-ខេត្តពោធិ៍សាត់ មាន** : ស្រុកភ្នំក្រវាញ ស្រុកវាលវែង

ស្រុកបាកាន : ឃុំតាលោ

ស្រុកក្រគរ : ឃុំឈើតុំ និង ឃុំស្វាយស

**-ខេត្តកំពង់ធំ មាន** : ស្រុកសណ្ដាន់ ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្គ

ស្រុកកំពង់ស្វាយ : ឃុំផាត់សណ្ដាយ

ស្រុកស្ទោង : ឃុំពាមបាង ឃុំពពក ឃុំបន្ទាយស្ទោង និងឃុំចំណារលើ

ស្រុកបារាយណ៍ : ឃុំគគីធំ និងឃុំបាក់ស្នា

ស្រុកសន្ទុក : ឃុំទិពោ និង ឃុំក្រយា

**-ខេត្តបាត់ដំបង មាន** : ស្រុករតនមណ្ឌល ស្រុកបវេល ស្រុកសំពៅលូន ស្រុកភ្នំព្រឹក្ស ស្រុកកំរៀង ស្រុកគាស់ក្រឡ ស្រុកសំឡូត

ស្រុកឯកភ្នំ : ឃុំកោះជីវាំង និង ឃុំព្រៃចាស់

ស្រុកមោងឫស្សី : ឃុំ ព្រៃត្រឡាច

**-ខេត្តសៀមរាប មាន** : ស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកវ៉ារិន ស្រុកអង្គរជុំ ស្រុកអង្គរធំ

ស្រុកបន្ទាយស្រី : ឃុំឃុនរាម ឃុំរំចេក ឃុំត្បែង និងឃុំរន្ធតាអក

ស្រុកជីក្រែង : ឃុំអន្លង់សំណរ ឃុំខ្នាវ ឃុំគោកធ្លកលើ ឃុំពង្រលើ ឃុំពង្រក្រោម ឃុំឫស្សីលក ឃុំល្វែងឫស្សី ឃុំស្ពានត្នោត និងឃុំសង្វើយ

ស្រុកក្រឡាញ់ : ឃុំរោងគោ ឃុំស្ពួល ឃុំក្រូចគោ ឃុំសែនសុខ និងឃុំសំបួរ

ស្រុកសូត្រនិគម : ឃុំពពេល ឃុំចាន់សរ ឃុំខ្នារពោធិ៍ ឃុំតាយ៉ែត និងឃុំកំពង់ឃ្លាំង

ស្រុកពួក : ឃុំកែវពណ៌ ឃុំរើល ឃុំត្រើវ ឃុំល្វា ឃុំយាង ឃុំក្តិរុន ឃុំពោធិ៍ទ្រាយ និងឃុំដូនកែវ

ស្រុកសៀមរាប : ឃុំនគរធំ និងឃុំចុងឃ្នៀស

ស្រុកប្រាសាទបាគង : ឃុំអំពិល ឃុំបល្ល័ង្គ និងឃុំកំពង់ភ្លុក

**-ខេត្តកំពង់ចាម មាន** : ស្រុកតំបែរ

ស្រុកមេមត់ : ឃុំទ្រាក ឃុំរូង ឃុំចាន់មូល ឃុំជាំ ឃុំជាំក្រវៀន ឃុំទន្លូង ឃុំជាំតាម៉ៅ ឃុំ ត្រម៉ោង ឃុំ មេមង ឃុំគគីរ ឃុំកំពាន់ និង ឃុំរំចេក

ស្រុកស្ទឹងត្រង់ : ឃុំអូរម្លូរ ឃុំដងក្តារ ឃុំ អារក្សត្នោត និងឃុំខ្ពបតាងួន

ស្រុកចំការលើ : ឃុំតាប្រុក និងឃុំចំការអណ្តូង

ស្រុកត្បូងឃ្មុំ : ឃុំថ្មពេជ្រ ឃុំគរ និងឃុំល្វៀង

ស្រុកពញាក្រែក : ឃុំវាលម្លូរ ឃុំកក់ និងឃុំត្រពាំងផ្លុង

**-ខេត្តបន្ទាយមានជ័យ មាន** : ស្រុកម៉ាឡៃ ស្រុកថ្មពួក ស្រុកភ្នំស្រុក

ស្រុកព្រះនេត្រព្រះ : ឃុំរហាល ឃុំទឹកជោរ ឃុំប្រាសាទ ឃុំទានកាំ និងឃុំភ្នំលៀប

ស្រុកអូរជ្រៅ : ឃុំអូរបីជាន់ ឃុំនិមិត្ត ឃុំសឹង្ហ ឃុំសំរោង និង ឃុំប៉ោយប៉ែត

ស្រុកសិរីសោភ័ណ : ឃុំបុសស្បូវ

ស្រុកមង្គលបូរី : ឃុំសំបួរ ឃុំគោកបល្ល័ង្គ ឃុំសឿ និងឃុំចំណោម

**-ខេត្តកំពង់ស្ពឺ មាន** : ស្រុកថ្ពង ស្រុកឱរ៉ាល់

ស្រុកភ្នំស្រួច : ឃុំមហាសាំង និងឃុំជាំសង្កែ

ស្រុកបរសេដ្ឋ : ឃុំកាត់ភ្លុក ឃុំភក្តី ឃុំកក់ និង ព្រះខែ

ស្រុកច្បារមន : ឃុំទំព័រមាស និងឃុំតាំងក្រូច

ស្រុកឧដុង្គ : ឃុំជម្ពូព្រឹក

**-ខេត្តក្រចេះ មាន** :

ស្រុកស្នួល : ឃុំស្រែចារ និងឃុំខ្សឹម

ស្រុកសំបូរ : ឃុំរលួស ឃុំស្រែជិះ ឃុំបឹងចារ ឃុំអូគ្រៀង និង ឃុំក្បាលដំរី

ស្រុកឆ្លូង : ឃុំកំពង់ដំរី និងឃុំដំរីផុង

**-ខេត្តកំពត មាន** : ស្រុកដងទុង ស្រុកជុំគីរី

ស្រុកឈូក : ឃុំល្បើក ឃុំកោះស្លា និង ឃុំត្រពាំងឃ្លាំង

ស្រុកកំពត : ឃុំស្ទឹងកែវ ឃុំព្រៃថ្នង់ និង ឃុំតំបន់ជាប់ព្រំដែន

ស្រុកកំពង់ត្រាច :ឃុំឫស្សីស្រុកខាងជើង ឃុំបឹងសាលាខាងត្បូង ឃុំបឹងសាលាខាងជើង និងឃុំព្រែកក្រើស

ស្រុកបន្ទាយមាស : ឃុំត្នោតចុងស្រង់ ឃុំ ព្រៃទន្លេ ឃុំ បន្ទាយមាសខាងលិច ឃុំបន្ទាយមាសខាងកើត និងឃុំស្ដេចគង់ខាងត្បូង

**-ខេត្តតាកែវ មាន** : ស្រុកបូរីជលសារ និង ស្រុកកោះអណ្ដែត

**-ខេត្តកណ្ដាល មាន** :

ស្រុកលើកដែក : ឃុំក្អមសំណរ

ស្រុកកោះធំ : ឃុំព្រែកជ្រៃ ឃុំសំពៅពូន និង ឃុំលើកដែក

ស្រុកស្អាង : ឃុំប្រាសាទ

ស្រុកល្វាឯម : ឃុំបារុង ឃុំព្រែកឫស្សី និង ឃុំកោះកែវ

ស្រុកមុខកំពូល : ឃុំស្វាយអំពារ

ស្រុកខ្សាច់កណ្ដាល : ឃុំជ្រៃធំ

ស្រុកពញាឮ : ឃុំកំពង់ហ្លួង និងឃុំកោះចិន

**-ខេត្តព្រៃវែង មាន** : ស្រុកព្រះស្ដេច ស្រុកពាមជរ

ស្រុកកំពង់ត្របែក : សាលារៀននៅក្នុងឃុំជាប់ព្រំដែនវៀតណាម

ស្រុកពារាំង : ឃុំមេប្រចាន់

ស្រុកស៊ីធរកណ្ដាល : ឃុំព្នៅទី ពីរ

**-ខេត្តកំពង់ឆ្នាំង មាន** : ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ស្រុកជលគីរី

ស្រុកកំពង់ត្រឡាច : ឃុំអំពិលទឹក

ស្រុកកំពង់លែង : ឃុំផ្លូវទឹក ឃុំប្រឡាយមាស ឃុំច្រណូក និង ឃុំសំរោងសែន

ស្រុករលាប្អៀរ : ឃុំ ប្រស្នឹប

ស្រុកបរិបូរណ៍ : ឃុំ កំពង់ព្រះ ឃុំគគី ឃុំអញ្ចាញរូង ឃុំប្រពេចចង្វារ និងឃុំត្រពាំងចាន់

-**ខេត្តស្វាយរៀង មាន** : សាលារៀនដែលនៅក្នុងឃុំជាប់ព្រំដែនវៀតណាម

ស្រុកចន្ទ្រា : ឃុំសំរោង ឃុំទួលស្តី ឃុំចន្ទ្រា

ស្រុកស្វាយទៀប : ឃុំមនោរម្យ ឃុំតានី

ស្រុករមាសហែក : ឃុំ គគីរ ឃុំត្រស់ ឃុំអណ្តូងត្របែក និងឃុំសម្បត្តិមានជ័យ

-**ក្រុងកែប មាន** : ខ័ណ្ឌកែប និងខ័ណ្ឌដំណាក់ចង្អើរ

-**ក្រុងព្រះសីហនុ មាន** : ខ័ណ្ឌមិត្តភាព : សង្កាត់កោះកុង

ខ័ណ្ឌព្រៃនប់ : សង្កាត់ព្រៃនប់ ។

**ប្រការ៤** : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានបណ្តុះបណ្តាលវិក្រឹតការ នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុងពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខានិងត្រា

**តុល ឡោះ**

## ៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

¤¤¤¤

ភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០[illegible]

**សេចក្តីសំរេច លេខ ១៦៥ ក.ធ.ស.ស.រ**

~~~~

### ក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
~~~~